# ប្រវត្តិស្នេហាមួយនៅលើដងទន្លេមេគង្គនៃកម្ពុជា
## ក្រមុំបារាំង - បុរសចាម

**ដោយ អេមីកូ ស្តក់** (១៩-១២-២០០៨)



*«កាលពីព្រេងនាយ មានដំណាលថា មានក្រមុំជនជាតិបារាំងដ៏ស្រស់សោភាមួយរូបស្ថិតនៅក្នុងសភាពភិតភ័យ កំពុងតែរត់គេចខ្លួនចេញពីការតាមដេញចាប់របស់ពួកជប៉ុន នៅតាមដងទន្លេមេគង្គ នៅខេត្តកំពង់ចាម។ យុវតីរូបនោះរស់នៅតែខ្លួនមួយ គ្មានឪពុកម្តាយឡើយ (ឪពុកម្តាយជាអ្នកដាំកៅស៊ូ)។ តួឯងស្រីដ៏កំសត់របស់យើងបានរត់រហូតមកទល់នឹងមាត់ទន្លេ ក៏ទ័លច្រករត់ទៅណាលែងរួច។ ក្តីសង្ឃឹមប្រែរលាយសាបសូន្យអស់ទៅហើយ។ រំពេចនោះ ស្រាប់តែមានបុរសអ្នកនេសាទជនជាតិចាមដ៏ស្រស់សង្ហាវ័យក្មេងមួយរូប បានអុំទូកមកដល់ ហើយក៏បានជួយសង្គ្រោះនាងពីសត្រូវ ។ កំលោះក្រមុំមួយគូនេះបានជិះទូកឆ្លងកាត់រលកទន្លេតិចៗ ... សេចក្តីស្នេហាក៏ចាប់ប៉ិចពន្លកឡើង ... ទូកបានចូលចតនៅមាត់ច្រាំងទន្លេ នាភូមិទ្រា គឺនៅទីនោះហើយ ដែលពួកគេទាំងពីរបានសម្រេចចិត្តរៀបការជាមួយគ្នា រស់នៅយ៉ាងសុខសាន្ត បង្កើតបានកូនចៅជាច្រើន...»។*

*តើនេះគឺជាទំព័របើកកកាយប្រលោមលោកស្នេហាមួយ រឺជាទំព័រមួយដែលដកស្រង់ចេញពីប្រជុំរឿងព្រេងទិនាន ដើម្បីបំភ័ន្តក្មេងៗ? រឺមួយជាសាច់រឿងដ៏ផ្អែមល្ហែមមួយ ដែលត្រូវចាក់បញ្ចាំងនៅក្នុងរោងភាពយន្ត។ ការស្មានទាំងអស់នេះសុទ្ធតែមិនពិត! ប្រវត្តិស្នេហ៍របស់ក្រមុំបារាំងដ៏ស្រស់ប្រិមប្រិយនិងព្រះអង្គម្ចាស់ជនជាតិចាមដ៏ស្រស់សង្ហាររបស់នាង ត្រូវបានចាស់ៗលើកយកមកនិទាននៅក្នុងពិភពជនជាតិចាម ទូទាំងប្រទេសកម្ពុជា ប្រៀបបានដូចជាគូស្នេហ៍នេះគឺជាផ្នែកមួយនៃប្រពៃណីរបស់ពួកគេ ។ ពួកគេបាននិទានប្រវត្តិស្នេហាផ្សងព្រេងមួយនេះ ហាក់បីដូចជាធ្លាប់បានស្គាល់ «ក្រមុំបារាំង» និងវីរៈបុរសជនជាតិចាមរបស់នាង ប៉ុន្តែគ្មាននរណាម្នាក់បានដឹងអំពីសាច់រឿងបន្តមកទៀតនៃគូស្នេហ៍ក្នុងទេវកថានេះនោះទេ។ ព្រេងនិទាននេះគឺជាផ្នែកខ្វះនៃប្រលោមលោកស្នេហាកម្ពុជា យុទ្ធកថាចាម និងប្រលោមលោកបារាំងឥណ្ឌូចិន។ តើរឿងព្រេងនិទាននេះត្រូវបានសរសេរឡើង ដោយផ្អែកលើការពិតមួយដែររឺទេ?*



នៅភូមិទ្រា ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម  គេមានការព្រួយបារម្ភផ្សេង ក្រៅពីការរៀបរាប់រឿងព្រេងនិទានចំណាស់និងល្បីសុះសាយមួយនេះ។ ទួន (គ្រូបង្រៀនឥស្លាម) បានចង់ចិញ្ចើម មានទឹកមុខមិនសូវសប្បាយរីករាយ នៅពេលឮគេនិយាយអំពីសាវតាស្នេហានេះ ព្រោះថាប្រវត្តិស្នេហានេះពិតជាកើតមានឡើងនៅទីនេះ។  ប្រសិនជាគេស្គាល់តួអង្គនៅក្នុងរឿងព្រេងនិទានទាំងនេះច្បាស់ ក៏ដោយសារទីនេះជាកន្លែងដែលពួកគេធ្លាប់រស់នៅ គឺនៅមាត់ច្រាំងទន្លេមេគង្គ។ នៅមាត់ច្រាំងនេះ ក៏មានទូកចម្លងមួយ ដែលអាចផ្ទុកមនុស្សបានច្រើនជាងទូករបស់អ្នកនេសាទវ័យក្មេងរបស់យើង ផងដែរ។

ដូចនេះ ម៉ី ប៊ី និង តាអាម៉ាត់ ពិតជាមានប្រាកដមែន។  ប៉ុន្តែខុសគ្នាពីតួអង្គនៅក្នុងរឿងព្រេងនិទាន តួអង្គទាំងពីររបស់យើងពិតជាមាន ប៉ុន្តែពួកគេមិនមែនជាមនុស្សអមតៈនោះទេ។ ពួកគាត់ទាំងពីរបានលាចាកលោកយើងនេះទៅហើយ។ ជាមួយនឹងស្នាមញញឹម ក្មួយស្រីម្នាក់ក្នុងចំណោមក្មួយស្រីរបស់ពួកគាត់ ស្ថិតក្នុងវ័យ៧០ឆ្នាំ ដែលនៅតែរស់នៅក្នុងផ្ទះពីកុមារភាពរបស់ខ្លួន បានអះអាងពីរឿងរ៉ាវស្នេហាដ៏អាថ៌កំបាំងនេះ។ លោកយាយត្រូវជាក្មួយរូបនេះបានបង្ហាញអាល់ប៊ុមរូបថត ដោយបានរម្លឹកទាំងស្រពិចស្រពិលនូវប្រវត្តិរបស់ពូមីងរបស់គាត់ ។

លោកយាយ ម៉ី ខាឌីយ៉ា បានរៀបរាប់ថា  «អូហ៍ ពូរបស់ខ្ញុំ... គាត់គឺជាមនុស្សល្បី! គឺជាបុរសមានអំណាច និងត្រូវបានគេគោរពបំផុត។ គេនិយាយថាគាត់គឺជាជនជាតិអារ៉ាប់... ជាមនុស្សម្នាក់ ក្នុងចំណោមអ្នកដែលគេភ័យខ្លាច។ គាត់ក៏ល្បីថាកាចគួរសមផងដែរ...»។ គាត់គឺជាអាជីវករដ៏រីករាយ ជាប្រធានព្រះវិហារឥស្លាម ឬជាមន្ត្រីរាជការនៅសម័យអាណាព្យាបាលបារាំង។ ប្រភពដើមដ៏ចម្លែកនិងស្រពិចស្រពិលរបស់ពូ អ៊ុងអាម៉ាត់ អាចបញ្ជាក់បានថា គាត់មិនមែននៅក្មេង ដូចបុរសអ្នកជួយសង្គ្រោះក្រមុំបារាំងនៅក្នុងរឿងព្រេងនិទាននោះទេ។ គាត់គឺជាបុរសវ័យចំណាស់ ហើយបុព្វបុរសរបស់គាត់មានកេរ្តិ៍ឈ្មោះល្បីល្បាញគួរសម នៅក្នុងចំណោមខ្មែរឥស្លាម ក៏ដូចជានៅចំណោមពុទ្ធសាសនិក។ ដូនតារបស់គាត់មកពីពិភពអារ៉ាប់និងឥណ្ឌា។  ជំនាញនិងទេពកោសល្យបន្សល់ទុកពីដូនតាដ៏អាថ៌កំបាំង ស្ថិតនៅលាយឡំនៅក្នុងរូបភាពរបស់ «តាអារ៉ាប់» ក៏ដូចជានៅក្នុងរូបភាពរបស់អ៊ុងអាម៉ាត់។

ជាការពិតណាស់ ក្រមុំស្បែកសរូបនេះបានក្លាយជាស្រីស្នេហ៍ទី២ របស់បុរសខ្លាំងយើង។ ក្មួយស្រី មុី ខាឌីយ៉ា បានរំឭកថា «គាត់គឺជាបុរសដែលមានភរិយាច្រើន  នេះគឺជាការពិត ... ដំបូងឡើយ គាត់រៀបការជាមួយស្ត្រីជនជាតិចាម រួចមកក៏មានកូន។ ក្រោយមករៀបការជាមួយស្ត្រីខ្មែរ ក៏មានកូនដែរ ហើយរៀបការជាមួយជនជាតិចិន... ក៏មានកូនដែរ ... ជាចុងក្រោយរៀបការជាមួយស្ត្រីបារាំង ក៏មានកូនទៀត... នៅមានទៀត!...»
លោកយាយមុី ខាឌីយ៉ា បានបដិសេធរៀបរាប់ពង្សាវតាជំនាន់ក្រោយរបស់ពូគាត់។



នៅប្រទេសបារាំង ទីក្រុងប៉ារីស អ្នកស្រី អ៊ុម កាទី អាយុ៩៣ឆ្នាំ ចៅស្រីរបស់ប្តីប្រពន្ធមួយគូនេះ នៅចងចាំជីដូនដែលគាត់ធ្លាប់រស់នៅជាមួយកាលពីកុមារភាព។ «ការពិត ជីតារបស់ខ្ញុំបានចាប់ជំរត់លោកយាយខ្ញុំឈ្មោះ មុី ប៊ី។  កាលនោះ នៅពេលចេញពីសាលារៀន និស្សិតដ៏ស្រស់សោភាឈ្មោះ ហ្គាប្រ៊ីយ៉ែល ព្យាណែត ត្រូវបានចាប់ជំរត់ដោយអនាគតស្វាមីរបស់គាត់ ... លោកតាបាននាំលោកយាយមកកាន់ទីក្រុងភ្នំពេញ និងបានយកគាត់ធ្វើជាភរិយា។ ពេលនោះ លោកយាយ មានអាយុ១៦ឆ្នាំ...»។  រឿងរ៉ាវនេះកើតមានឡើងនៅប្រហែលជាឆ្នាំ១៩១៥ គឺមុនសង្គ្រាមលោកលើកទីពីរ និងមុនការឈ្លានពានរបស់ពួកជប៉ុនដែលត្រូវបានគេដំណាលនៅក្នុងរឿងព្រេងនិទាន។

នៅកូមិទ្រា «យុវតីជនជាតិបារាំង» បានប្រែក្លាយយ៉ាងឆាប់រហ័សជា «យុវតីចាម»។ ត្រង់នេះហើយដែលចាស់ៗចងចាំ។ គាត់បានគោរពសាសនាឥស្លាមតាមស្វាមីរបស់គាត់ ដែលជាប្រធានវិហារឥស្លាម។ គាត់គ្មានអ្វីត្រង់ណា ដែលខុសប្លែកពីអ្នកជិតខាងរបស់គាត់នោះទេ។ គាត់ពាក់ស្បៃមុខលើក្បាល ស្លៀកសារុងដូចគេឯង។ គាត់បានប្តូរឈ្មោះកំណើតពី ហ្គាប្រ៊ីយ៉ែល ព្យាណែត មកជាឈ្មោះ «មុី ប៊ី» និង «យ៉េយ ហ្គាហ៍»។

យុវតីបារាំងម្នាក់នេះ បានស្ម័គ្រចិត្តរួមសម្ព័ន្ធមេត្រីជាមួយបុរសចាម យ៉ាងឆាប់រហ័ស គួរអោយភ្ញាក់ផ្អើល។ «យើងមិនដឹងមូលហេតុអ្វីបាន ជាគាត់យល់ព្រមដូច្នេះនោះទេ។ គាត់តែងតែនិយាយប្រាប់ខ្ញុំថាជីតា របស់ខ្ញុំ «បានបង្កើតមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅចំពោះរូបគាត់» ហើយគាត់ក៏ចុះចាញ់សេចក្តីស្នេហារបស់ជីតាខ្ញុំភ្លាម។ ឪពុកម្តាយរបស់ គាត់ ដែលប្រហែលជាមន្ត្រីរាជការផ្នែករដ្ឋបាលនៅទីក្រុងភ្នំពេញ មិន បានជំទាស់នឹងស្នេហានេះនោះទេ ហើយក៏យល់ព្រមអោយអ្នកទាំងពីរ រៀបមង្គលការ។



ហ្គាប្រីយ៉ែល ព្យាណៃត ហៅ ម៉ី ប៊ី - © គ្រួសារ ម៉ូសា

ដោយស្នាក់នៅគេហដ្ឋានក៏ធំមួយ នៅមាត់ទន្លេ នាភូមិទ្រា ម៉ី ប៊ី បាន ប្រែក្លាយជាជនជាតិចាម និយាយភាសាចាម ក៏ដូចជាភាសាចិន និងខ្មែរ បានយ៉ាងស្ទាត់ជំនាញ។ គាត់និយាយភាសាចាមជាមួយចៅៗរបស់គាត់ នៅទីក្រុង ដើម្បីកុំអោយពួកគេភ្លេចភាសាកំណើតរបស់ខ្លួន។ ប៉ុន្តែ ម៉ី ប៊ី នៅតែសរសេរជាភាសាបារាំងដដែល។ គាត់បានជម្រុញអោយចៅស្រី របស់គាត់បន្តការសិក្សានៅវិទ្យាល័យបារាំង នាទីក្រុងភ្នំពេញ និងមាន ទំនាក់ទំនងមិត្តភាព ជាមួយអាចារ្យម្នាក់នៅរាជធានី។

នៅឆ្នាំ១៩៧៤ ស្ថិតក្នុងវ័យ៧៦ឆ្នាំ លោកយាយ ហ្គាប្រីយ៉ែល ព្យាណៃត បានទទួលមរណៈភាព តាមស្វាមីរបស់គាត់ ដែល បានបាត់បង់ជីវិតអស់រយៈពេលប៉ុន្មានឆ្នាំមុន។ គាត់ត្រូវបានបញ្ចុះសពដោយបងប្អូនប្រុសស្រីរបស់គាត់ដែលមកពីប្រទេស បារាំង ដើម្បីឧទ្ទិសកុសលជាចុងក្រោយដល់គាត់។ រឿងដំណាលប្រវត្តិបានមិននិយាយថាតើសាកសពរបស់លោកយាយ ត្រូវបញ្ចុះនៅក្រោមរូបឈើឆ្កាងបែបគ្រិស្តសាសនានៅភ្នំពេញ រឺនៅក្នុងផ្នូរសពឥស្លាមសាសនានៅភូមិទ្រានោះទេ។



ជាចុងក្រោយ រឿងព្រេងនិទានបានផ្អែកលើប្រវត្តិពិតនេះ ដោយបានបង្កើតជាបរិបទជាច្រើនខុសៗគ្នា៖ សត្រូវជប៉ុនរួមមួយ, អ្នកគ្រប់គ្រងរដ្ឋបាលប្រែក្លាយជាអ្នកដាំដំណាំកៅស៊ូ, អ្នកនេសាទម្នាក់ដែលពោរពេញដោយអំណាចនិងភាពអាថ៌កំបាំង, ស្ត្រីជនជាតិស្បែកសរស់នៅសម្របទៅតាមបរិយាកាសនៅតាមដងទន្លេមេគង្គ...។ ជាការពិតណាស់ សម្ព័ន្ធភាពរវាងម៉ុ ប៊ី និងតាអាម៉ាត់ គឺជាសម្ព័ន្ធស្នេហាមួយនៅក្នុងរឿងប្រលោមលោកខ្មែរ រឿងយុទ្ធកថាចាម និងប្រលោមលោកឥណ្ឌូចិន...។ នេះគ្រាន់តែជាការផ្សព្វផ្សាយនូវប្រវត្តិស្នេហាដ៏ល្បីឈ្មោះមួយប៉ុណ្ណោះ!